**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៚ៜៜ៚

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃព្រហស្បតិ៍ ៦ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់ នៅទីស្នាក់ការក្រុមហ៊ុន ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លោក **Yang, Po-Yu** ជាប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់សិទ្ធជាប្រធានមហាសន្និបាតភាគហ៊ុនិក លើកទី៩ (“**មហាសន្និបាតភាគហ៊ុនិក**”) និងបានដឹកនាំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុននេះ។

## សមាសភាពចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក

១. គណៈអធិបតី និងភ្ញៀវកិត្តិយស
២. ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន
៣. គណៈកម្មការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត
៤. ភាគហ៊ុនិករបស់ក្រុមហ៊ុនដែលមានរាយនាមក្នុងបញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣*។

* បញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ភាគហ៊ុនិកសរុប មានចំនួន **១.៣៧២ នាក់**។

- ចំនួនភាគហ៊ុនិកសរុប ដែលបានចុះឈ្មោះចូលរួមប្រជុំមហាសន្និបាត៖ ចំនួន **២៤ នាក់** (គិតជាភាគហ៊ុន មានចំនួន **៣៤.០៨២.៣២៧** ភាគហ៊ុន) ស្មើនឹង <u>៨៥,២១</u> % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកសរុប ដែលមានវត្តមាន នាថ្ងៃមហាសន្និបាត៖ ចំនួន **១២ នាក់** (គិតជាភាគហ៊ុន មានចំនួន **២៨.៣៩៨.៦៧០** ភាគហ៊ុន) ស្មើនឹង **៧១%** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះ តែអវត្តមាន នាថ្ងៃប្រជុំមហាសន្និបាត៖ ចំនួន **១២ នាក់** (គិតជាភាគហ៊ុន មានចំនួន **៥.៦៨៣.៦៥៧** ភាគហ៊ុន) ស្មើនឹង **១៤,២១%** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកសរុបដែលអវត្តមាន នាថ្ងៃមហាសន្និបាត៖ ចំនួន **១.៣៦០ នាក់** (គិតជាភាគហ៊ុន មានចំនួន **១១.៦០១.៣៣០** ភាគហ៊ុន ស្មើនឹង **២៩%** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(៨៥៥)២៣ ៨៩០ ៣២៥ /ទូរសារ :(៨៥៥)២៣ ៨៩០ ៣២៦ / គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com

## របៀបវារៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

| | |
|---|---|
| ម៉ោង ៨:០០ - ៩:០០ | ការចុះឈ្មោះ |
| ម៉ោង ៩:០០ - ៩:៣០ | ប្រកាសហេតុ និងមតិស្វាគមន៍បើកកម្មវិធីដោយអ្នកតំណាងក្រុមហ៊ុន |
| ម៉ោង ៩:៣០ - ១០:៣០ | បទបង្ហាញស្តីពីរបាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ ២០២២ និងឆ្នាំ២០២៣ |
| ម៉ោង ១០:៣០ - ១០:៤៥ | សម្រាកពិសាអាហារសម្រន់ |
| ម៉ោង ១០:៤៥ - ១១:៤៥ | កម្មវិធីបោះឆ្នោត<br>▪ ការបន្តអាណត្តិបន្ថែមសម្រាប់អភិបាល<br>▪ ការបែងចែកភាគលាភជូនភាគហ៊ុនិក<br>▪ ការបែងចែកលាភការសម្រាប់អភិបាល<br>▪ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន<br>▪ ប្រកាសលទ្ធផលបោះឆ្នោត |
| ម៉ោង ១១:៤៥ - ១២:០០ | មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ |

ការបន្តអាណត្តិបន្ថែមសម្រាប់អភិបាលរបស់ក្រុមហ៊ុន សម្រាប់ ៣ឆ្នាំ ដែលបានស្នើដោយក្រុមប្រឹក្សាភិបាលត្រូវបានអនុម័ត និងសម្រេច ដោយសម្លេងបោះឆ្នោតភាគច្រើនរបស់ភាគហ៊ុនិក ដែលមានសិទ្ធបោះឆ្នោត និងមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន ដូចខាងក្រោម ៖

- លោក CHEN TSUNG-CHI ជា អភិបាលប្រតិបត្តិ
- លោកស្រី WANG, YI-TING ជា អភិបាលប្រតិបត្តិ
- លោក HUANG, TUNG-FU ជា អភិបាលមិនប្រតិបត្តិ

ការបែងចែកភាគលាភជូនភាគហ៊ុនិក និងលាភការសម្រាប់អភិបាលរបស់ក្រុមហ៊ុន ត្រូវបានយល់ព្រម និងអនុម័តដោយសម្លេងបោះឆ្នោតភាគច្រើនរបស់ភាគហ៊ុនិក ដែលមានសិទ្ធបោះឆ្នោត និងមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន ដូចខាងក្រោម ៖

ភាគលាភជាសាច់ប្រាក់ចំនួន **១.៦០០.០០០.០០០ រៀល** ប្រមាណ **៤០០.០០០ដុល្លារអាមេរិក** ស្មើនឹង **៤៥,៨៩%** នៃប្រាក់ចំណេញក្រោយបង់ពន្ធប្រចាំឆ្នាំ២០២២ នឹងត្រូវបែងចែកជូនភាគហ៊ុនិក នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

១- ប្រភេទភាគលាភដែលបែងចែក : ជាសាច់ប្រាក់

២- រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២២

៣- អនុបាតនៃការសងភាគលាភ : ៤៥,៨៩% នៃប្រាក់ចំណេញក្រោយបង់ពន្ធ ប្រចាំឆ្នាំ២០២២

៤- ភាគលាភសរុបដែលបែងចែក : ១.៦០០.០០០.០០០ រៀល

៥- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ : ៤០ រៀល

៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភៈ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣

៧- ការបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភៈ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣

លាភការ ជាសាច់ប្រាក់ចំនួន **២៤០.០០០.០០០ រៀល** ប្រមាណជា **៦០.០០០ ដុល្លារអាមេរិក** ត្រូវប្រកាសចែកជូនក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនត្រូវបានយល់ព្រម និងអនុម័តដោយសម្លេងបោះឆ្នោតច្រើនជាង ២/៣ របស់ភាគហ៊ុនិកដែលមានសិទ្ធបោះឆ្នោត និងមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិក របស់ក្រុមហ៊ុនផងដែរ។

ក្នុងមហាសន្និបាតភាគហ៊ុនិកនេះ អង្គប្រជុំបានធ្វើបទបង្ហាញពីខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០២២ និងផែនការសម្រាប់ឆ្នាំ២០២៣ នេះ និងកិច្ចពិភាក្សាលើបញ្ហាផ្សេងៗរបស់ក្រុមហ៊ុន រួមមាន ផែនការនៃការបោះផ្សាយមូលបត្របំណុលដែលអាចបដិវត្តន៍ជាភាគហ៊ុន ត្រូវបានលើកយកមកពិភាក្សា អនុម័ត និងសម្រេចដោយភាគហ៊ុនិក ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនផងដែរ។

មហាសន្និបាតភាគហ៊ុនិកនេះ បានបញ្ចប់ទៅនៅវេលាម៉ោង ១២:០០ ថ្ងៃត្រង់ នាថ្ងៃខែឆ្នាំ ដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**